# កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស)

## <u>សេចក្តីប្រកាសអំពីការធ្វើរ៉ូដស្វូ (Roadshow)</u>

## <u>និងការធ្វើប៊ុកបៀលឌីង</u>

កំពង់ផែស្វយ័តក្រុងព្រះសីហនុ (ក.ស.ស) ជាសហគ្រាសបោះផ្សាយលក់មូលបត្រ និងក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី ដែលជាក្រុមហ៊ុនធានាទិញមូលបត្រ សូមជូនដំណឹងដល់វិនិយោគិនទាំងអស់ពីការចាប់ផ្តើមការធ្វើរ៉ូដស្វូ និងធ្វើប៊ុកបៀលឌីង សម្រាប់កំណត់ថ្លៃបោះផ្សាយលក់មូលបត្រកម្មសិទ្ធិលើកដំបូងជាសាធារណៈ (IPO) របស់ ក.ស.ស ចំនួន ២១.៤៤២.៩៩២ ភាគហ៊ុន នៃភាគហ៊ុនមានសិទ្ធិបោះឆ្នោតសរុបចំនួន ៨៥.៧៧១.៩៦៧ ភាគហ៊ុន ដែលនឹងគ្រោងធ្វើការចុះបញ្ជីលក់នៅក្នុងផ្សារមូលបត្រកម្ពុជា។ វិនិយោគិនដែលមានបំណង់ចូលរួមក្នុងការធ្វើប៊ុកបៀលឌីង និងការបោះផ្សាយលក់មូលបត្ររបស់ ក.ស.ស សូមដាក់ពាក្យស្នើសុំធ្វើប៊ុកបៀលឌីងនៅទីកន្លែងធ្វើប៊ុកបៀលឌីង។

**១. ចន្លោះថ្លៃលក់ភាគហ៊ុន÷** ពី ៣.៥២០ រៀល ដល់ ៥.១៨០ រៀល (០,៨៨ ដុល្លារអាមេរិក - ១,២៩ ដុល្លារអាមេរិក) ក្នុងមួយភាគហ៊ុនរបស់ ក.ស.ស

ក.ស.ស ជាមួយនឹងក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី នឹងកំណត់ថ្លៃលក់ភាគហ៊ុនដោយអនុលោមតាមគោលការណ៍ណែនាំស្តីអំពីការធ្វើប៊ុកបៀលឌីង និងការធ្វើបរិវិសកម្មមូលបត្រកម្មសិទ្ធិ។ ថ្លៃលក់ភាគហ៊ុន នឹងត្រូវប្រកាសក្រោយពីទទួលបានការអនុញ្ញាតលើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក។

**២. រ៉ូដស្វូ (Road Show)÷** ក.ស.ស នឹងរៀបចំរ៉ូដស្វូជាសាធារណៈដែលបង្ហាញអំពីអាជីវកម្ម និងគម្រោង IPO របស់ក្រុមហ៊ុន។

កាលវិភាគនៃការរៀបចំរ៉ូដស្វូមានដូចខាងក្រោម÷

ក. កាលបរិច្ឆេទ÷ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ ចាប់ពីម៉ោង ៩:០០ នាទីព្រឹក ដល់ ១២:០០ នាទីព្រឹក

ខ. ទីកន្លែង÷ Raffles Hotel Le Royal ភ្នំពេញ

## ៣. ការធ្វើប៉ុកបៀលឌីង÷

### ក. ការបែងចែកមូលបត្រកម្មសិទ្ធិ÷

| ល.រ | ក្រុមវិនិយោគិន | ចំនួនបែងចែក | ភាគរយ |
|---|---|---|---|
| ១ | មន្ត្រី និយោជិក | ២.១៤៤.២៩៩ | ១០% |
| ២ | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន JICA ជាវិនិយោគិនសក្តានុពល | ១១.៥៧៩.២១៦ | ៥៤% |
| ៣ | វិនិយោគិនក្នុងប៉ុកបៀលឌីង | ៥.៤០៣.៦៣៤ | ២៥,២% |
| ៤ | វិនិយោគិនក្នុងបរិវិសកម្ម | ២.៣១៥.៨៤៣ | ១០,៨% |
|  | សរុប | **២១.៤៤២.៩៩២** | **១០០%** |

### ខ. កាលបរិច្ឆេទ÷ ចាប់ពីថ្ងៃទី២៥ ខែមេសាដល់ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧

- ពេលព្រឹក÷ ចាប់ពីម៉ោង ០៨:០០ ដល់ម៉ោង ១២:០០
- ពេលថ្ងៃ÷ ចាប់ពីម៉ោង ១៣:០០ ដល់ម៉ោង ១៧:០០
- រាល់ពាក្យស្នើសុំដែលហួសពីថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៧ ម៉ោង ១៧:០០ (ម៉ោងនៅព្រះរាជាណាចក្រកម្ពុជា) នឹងចាត់ទុកជាអាសារបង់។

### គ. ទីកន្លែងធ្វើប៉ុកបៀលឌីង÷

| ល.រ | ឈ្មោះក្រុមហ៊ុន | គេហទំព័រ | ទូរស័ព្ទលេខ |
|---|---|---|---|
| ១ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យួរីធី | www.sbiroyal.com | (៨៥៥) ២៣ ៩៩៩ ៥៩៥ |
| ២ | អេស៊ីលីដា ស៊ីឃ្យួរីធី ភីអិលស៊ី | www.acledasecurities.com.kh | (៨៥៥) ២៣ ៩៩៩ ៩៦៦ |
| ៣ | កម្ពុ ស៊ីឃ្យួរីធី ភីអិលស៊ី | www.campusecurities.com.kh | (៨៥៥) ២៣ ៩៩៩ ៨៨០ |
| ៤ | កាណា ស៊ីឃ្យួរីធី អិលធីឌី | www.canasecurities.com.kh | (៨៥៥) ២៣ ៩៩៩ ៨៨៧ |
| ៥ | ហ្គោលដេន ហ្វ័រឈូន (ខេមបូឌា) ស៊ីឃ្យួរីធី ភីអិលស៊ី | www.goldenfortune.com.kh | (៨៥៥) ២៣ ២១៨ ២៨៨ |
| ៦ | ភ្នំពេញ ស៊ីឃ្យួរីធី ភីអិលស៊ី | www.pps.com.kh | (៨៥៥) ២៣ ៨៨៦ ៥៥៥ |
| ៧ | អ អេច ប៊ី ឥណ្ឌូឆៃណា ស៊ីឃ្យួរីធី លីមីធីត | www.rhbgroup.com | (៨៥៥) ២៣ ៩៦៩ ១៦១ |
| ៨ | យាន់តា ស៊ីឃ្យួរីធី (ខេមបូឌា) ភីអិលស៊ី | www.yuantacambodia.com | (៨៥៥) ២៣ ៨៦០ ៨០០ |

ឃ. នីតិវិធី÷

១) វិនិយោគិនត្រូវមានលេខអត្តសញ្ញាណវិនិយោគិនពី គ.ម.ក។

២) វិនិយោគិនត្រូវមានលេខគណនីជួញដូរមូលបត្រកម្មសិទ្ធិ (Securities Trading Account) នៅក្រុមហ៊ុនមូលបត្រណាមួយ ដែលបានទទួលអាជ្ញាប័ណ្ណពី គ.ម.ក។

៣) វិនិយោគិនត្រូវបំពេញពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីង (Book-building Application Form) នៅទីតាំងដូចបានបញ្ជាក់ខាងលើ។

៤) វិនិយោគិនត្រូវដាក់ពាក្យស្នើសុំចូលរួមធ្វើប៊ុកបៀលឌីងទៅកាន់ទីតាំងដូចបានបញ្ជាក់ខាងលើ និង**ដាក់ប្រាក់កក់ចំនួន ១០% នៃថ្លៃលក់ភាគហ៊ុនសរុបដែលបានបំពេញនៅក្នុងពាក្យស្នើសុំធ្វើប៊ុកបៀលឌីង។**

៤. **ការប្រកាសអំពីលទ្ធផលនៃការធ្វើប៊ុកបៀលឌីង÷** ក.ស.ស ជាមួយនឹងក្រុមហ៊ុន អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី នឹងប្រកាសអំពីលទ្ធផលនៃការធ្វើប៊ុកបៀលឌីងទៅកាន់វិនិយោគិន ក្រោយពីទទួលបានការអនុញ្ញាតលើសំណើសុំបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ និងការចុះបញ្ជីឯកសារផ្តល់ព័ត៌មានពី គ.ម.ក។ វិនិយោគិនដែលទទួលបានជោគជ័យនៅក្នុងប៊ុកបៀលឌីង សំដៅទៅលើវិនិយោគិនដែលបានដាក់ថ្លៃខ្ពស់ជាង ឬស្មើនឹងថ្លៃលក់ភាគហ៊ុន (Offering Price)។

សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើប៊ុកបៀលឌីង÷

| ល.រ | ឈ្មោះក្រុមហ៊ុន | គេហទំព័រ | អ៊ីម៉ែល | ទូរស័ព្ទលេខ |
|---|---|---|---|---|
| ១ | អេសប៊ីអាយ រ៉ូយ៉ាល់ ស៊ីឃ្យូរីធី | www.sbiroyal.com | info@sbiroyal.com | (៨៥៥) ២៣ ៩៩៩ ៥៩៥ |
| ២ | អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី | www.acledasecurities.com.kh | info@acledasecurities.com.kh | (៨៥៥) ២៣ ៩៩៩ ៩៦៦ |
| ៣ | កំពង់ផែស្វយ័តក្រុងព្រះសីហនុ | www.pas.gov.kh | pasinfo@pas.gov.kh | (៨៥៥) ៣៤ ៩៣៣ ៨១៦ |

**ក្រុមហ៊ុនធានាទិញមូលបត្រ**

SBI Royal Securities